ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សិកម្ម រុក្ខាប្រមាញ់ និង នេសាទ

: ០៤០ ប្រក. កសក

# ប្រកាស

## ស្តីពី

## ការចុះបញ្ជីសហគមន៍នេសាទចំនួន០៧ នៅខេត្តកំពង់ចាមនិងខេត្តបាត់ដំបង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្មនិងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

# សម្រេច

**ប្រការ ១.-**

ត្រូវបានចុះបញ្ជីជាផ្លូវការនិងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនូវសហគមន៍នេសាទចំនួន០៧ រួមមាន៖ ខេត្តកំពង់ចាម០៥ សហគមន៍នេសាទនិងខេត្តបាត់ដំបង០២ សហគមន៍នេសាទ ដែលមានឈ្មោះសហគមន៍នេសាទ ចំនួនសមាជិក ចំនួនគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះ ភូមិ ឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ដូចមាននៅក្នុងតារាង និងផែនទីកន្លែងនេសាទសហគមន៍នីមួយៗជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ។

**ប្រការ ២.-**

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗដែលបានកំណត់ក្នុងផែនទី ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវបានទទួលស្គាល់ដោយនាយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៣.-**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍ដូចមានចែងក្នុងប្រការ១ អាចកែប្រែបានតាមការចាំបាច់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និងប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត វ៉េង សាខុន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ: ភ្ជាប់ប្រកាសលេខ...០៤០ ប្រក.កសក.ចុះថ្ងៃទី...១២...ខែ.មករា..........ឆ្នាំ២០១៥

# សហគមន៍នេសាទក្នុងខេត្តកំពង់ចាម និងខេត្តបាត់ដំបង

| ល.រ | ឈ្មោះសហគមន៍នេសាទ | ចំនួនសមាជិក | ចំនួនសមាជិកគណៈកម្មការសហគមន៍ | ទំហំផ្ទៃសហគមន៍ (ហិកតា) | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង | Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N, Unit: Meter (X,Y) | (X,Y) |
|---|---|---|---|---|---|---|---|---|---|
| **១. ខេត្តកំពង់ចាម** | | | | | | | | | |
| ០១ | ខ្ពបតាងួន | ១៧៤ | ១១ | ១.៨៦១ | -ខ្ពបតាងួន<br>-អន្លង់សំឡី<br>-ព្រែកទក់<br>-អូររុន<br>-ឈើទើ | ខ្ពបតាងួន | ស្ទឹងត្រង់ | A(581442, 1358126)<br>B(578383, 1359355)<br>C(578218, 1359704) | D(579709, 1360449)<br>E(582168, 1363741)<br>F(584220, 1361311) |
| ០២ | ពាមកោះស្នា | ៣៥២ | ១១ | ៤.៧៤៦ | -ទួលរការ<br>-ព្រែកសង្កែកើត<br>-ពាមក្នុង<br>-កោះកណ្ដាល<br>-ស្រែសង្កែ<br>-ដីលើ<br>-ដីដុះ<br>-ព្រែកស្ដី<br>-ព្រះអណ្ដូងទី១<br>-ព្រះអណ្ដូងទី២ | -ពាមកោះស្នា<br>-ព្រះអណ្ដូង<br>-ទួលសំបូរ<br>-អារក្សត្នោត | ស្ទឹងត្រង់ | A(571635, 1367480)<br>B(575375, 1363482)<br>C(577545, 1361589)<br>D(574970, 1358214) | E(566396, 1361107)<br>F(567338, 1362691)<br>G(569624, 1364235)<br>H(571174, 1366532) |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | -ស្រែអំពៅ<br>-អារក្សត្នោត<br>-ល្វា | | | | |
| ០៣ | គ្រួសារបីឃុំ | ១.៣៤៥ | ១១ | ៣.៦២៧ | -ដូនទរ<br>-សំពៀងលើ<br>-ភូមិថ្មី<br>-តាមើង<br>-ភូមិវត្ត<br>-សំពៀងក្រោម<br>-ព្រៃកកក់<br>-ព្រៃកបាក់<br>-ព្រៃករលួស<br>-ព្រៃកព្រះអង្គ<br>-ភ្នំមន្ទីរ<br>-មាឃ១<br>-ព្រៃកបារាំង<br>-ត្នោតតាសាយ<br>-ទួលពោធិ៍<br>-ភូមិព្រះ<br>-អណ្តូងពេជ្រ | -ទួលព្រះឃ្លាំង<br>-ព្រៃកបាក់<br>-ព្រៃកកក់ | ស្ទឹងត្រង់ | A(557318, 1345037)<br>B(557415, 1349666)<br>C(558309, 1353663)<br>D(553898, 1354700)<br>E(552716, 1353502) | F(554123, 1353802)<br>G(554093, 1352980)<br>H(551985, 1351396)<br>I(553288, 1348044)<br>J(555958, 1346492) |
| ០៤ | រកាខ្នុរសែនជ័យ | ៤០៤ | ១១ | ៨០ | -ភូមិទី១<br>-ភូមិទី២<br>-ភូមិទី៣ | រកាខ្នុរ | ក្រូចឆ្មារ | A(582755, 1352042)<br>B(582909, 1351742)<br>C(583084, 1351584) | F(583134, 1350825)<br>G(583221, 1350548)<br>H(583499, 1350525) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | -ភូមិទី៤<br>-ភូមិទី៥<br>-ភូមិទី៦<br>-ភូមិទី៧ | | | D(582935, 1351256)<br>E(583048, 1350914) | I(583618, 1351328)<br>J(583415, 1351950) |
| ០៥ | បឹងយាយស | ២៣០ | ១១ | ១.០០០ | -ជីផាង<br>-រពាក់១<br>-ដង្កា<br>-ឈូងតាសៅ | សេដា | តំបែរ | A(596036, 1345649)<br>B(595991, 1346300)<br>C(596148, 1348271) | D(597022, 1349838)<br>E(593045, 1348416)<br>F(594557, 1347598) |
| ២. ខេត្តបាត់ដំបង | | | | | | | | | |
| ០១ | ទំពូងអង់ត្បូង | ៣៨០ | ០៩ | ៤.៧៨៨ | -ទំពូង<br>-អង់ត្បូង | តាពូង | ថ្មគោល | A(294550, 1466000)<br>B(303257, 1468144)<br>C(311050, 1469455) | D(306800, 1468500)<br>E(302500, 1463811)<br>F(300797, 1459999) |
| ០២ | ក្បាលគោល | ១៣៩ | ១១ | ១១.១៣០ | ក្បាលគោល | កោះជីវាំង | ឯកភ្នំ | A(353401, 1445310)<br>B(361037, 1448882)<br>C(368276, 1439214) | D(360355, 1433277)<br>E(354973, 1441119)<br>F(356021, 1445441) |

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៥
រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បណ្ឌិត អ៊ុក រ៉ាប៊ុន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

បណ្ឌិត ណៅ_ធួក